កោះសន្តិភាព

KOH SANTEPHEAP DAILY

ថ្ងៃអង្គារ ទី២៨ ខែសីហា ឆ្នាំ២០០៧

The Khmer Kampuchea Krom Community issues a reply in response to the Vietnamese ambassador to Cambodia in a news conference. Koh Santepheap 08/28/07

# សហគមន៍ខ្មែរកម្ពុជាក្រោមថ្លែងការណ៍ឆ្លើយតប ជុំវិញសន្និសីទសារព័ត៌មានរបស់មន្ត្រីស្ថានទូតវៀតណាម

**រាជធានីភ្នំពេញ :** សហគមន៍ខ្មែរកម្ពុជាក្រោមបានចេញសេចក្តីថ្លែងការណ៍មួយ ដោយបានសំដែងនូវការសោកស្តាយចំពោះការថ្លែង

ក្នុងសន្និសីទសារព័ត៌មានរបស់លោកង្វៀន ចៀនថាំង ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមដែលបានបណ្តាញសារព័ត៌មានចុះផ្សាយនៅក្នុងសន្និសីទការសែត កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ កន្លងទៅនេះ ។ សេចក្តីថ្លែងការណ៍ដែលចុះហត្ថលេខាដោយលោកថាច់ សេដ្ឋា បានចាត់ទុកថា នេះជាសកម្មភាពនយោបាយការទូតថ្មីមួយទៀតរបស់វៀតណាមក្នុងការបំភ្លៃការពិតដើម្បីបំភ័ន្តសាធារណមតិជាតិ និងអន្តរជាតិអំពីការរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសវៀតណាម ជាពិសេសចំពោះប្រជារាស្ត្រ និងព្រះសង្ឃខ្មែរកម្ពុជាក្រោម ។ ប្រសាសន៍របស់លោកង្វៀន ចៀនថាំង ពុំបានឆ្លុះបញ្ចាំងការពិតដែលកំពុងកើតមានចំពោះប្រជារាស្ត្រខ្មែរកម្ពុជាក្រោម និងព្រះសង្ឃខ្មែរកម្ពុជាក្រោមឡើយ ។

សហគមន៍ខ្មែរកម្ពុជាក្រោម ធ្វើការកត់សម្គាល់ប្រសាសន៍របស់លោកឯកអគ្គរដ្ឋទូតថា លោកទឹម សាខន កំពុងជាប់ឃុំឃាំងនៅប្រទេសវៀតណាម ក្រោមបទចោទប្រកាន់ថា "បានធ្វើឱ្យបែកបាក់ផ្ទៃកសាសនារវាងប្រទេសទាំងពីរ (កម្ពុជា-វៀតណាម)" ។ ការថ្លែងនេះផ្ទុយទាំងស្រុងនឹងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋាភិបាលវៀតណាមកាលពីថ្ងៃទី២ សីហា ឆ្នាំ២០០៧ ដែលបានចោទប្រកាន់លោកទឹម សាខន ថា "បានឆ្លងដែនចូលប្រទេសវៀតណាមដោយខុសច្បាប់ និងធ្វើសកម្មភាពបំបែកបំបាក់មិត្តភាព សាមគ្គីភាពកម្ពុជា-វៀតណាម" ។ ទោះបីការថ្លែងការណ៍មានការខុសគ្នាយ៉ាងណាក៏ដោយ ក៏ពុំមានភស្តុតាងណាមួយបញ្ជាក់ថា លោកទឹម សាខន បានប្រព្រឹត្តបទល្មើសណាមួយក្នុងទឹកដីវៀតណាម ឬនៅពីក្រោយខ្នងសកម្មភាពមួយណាក៏គ្មានដែរ ។ ការបំបែកបំបាក់ឬការកាត់ផ្តាច់ទំនាក់ទំនងព្រះពុទ្ធសាសនាខ្មែររវាងកម្ពុជា និងកម្ពុជាក្រោម មិនមែនលោកទឹម សាខន ទេ ។

ចំពោះការប្រកាសថា វៀតណាមបានគោរពសិទ្ធិសេរីភាពជំនឿសាសនារបស់ជនជាតិដើមទាំង៥៤សញ្ជាតិយ៉ាងត្រឹមត្រូវ រួមទាំងខ្មែរផង ត្រូវបានសេចក្តីថ្លែងការណ៍ច្រានចោលហើយបានអះអាងថា ដោយឡែកប្រជារាស្ត្រ និងព្រះសង្ឃខ្មែរកម្ពុជាក្រោម កំពុងទទួលរងនូវការរំលោភយ៉ាងធ្ងន់ធ្ងរ និងត្រូវបានកែប្រែទំនៀមទំលាប់ក្នុងព្រះពុទ្ធសាសនាចាប់បង្ខំព្រះសង្ឃឱ្យធ្វើពលកម្មដូចគ្រហស្ថមានជីកប្រឡាយ ធ្វើស្រែចំការចិញ្ចឹមសត្វពាហនៈរាល់កម្មវិធីបុណ្យទានតាមបែបសាសនាត្រូវបានកំណត់គ្រប់វត្តអារាមត្រូវបងវិភាគទានជូនរដ្ឋជាដើម ។ ថ្មីៗនេះអាជ្ញាធរវៀតណាមបានចាប់ព្រះសង្ឃខ្មែរកម្ពុជាក្រោមផ្សឹកចំនួន១៦អង្គ ហើយ៥អង្គត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារពី២ទៅ៤ឆ្នាំ សាលារៀនពុទ្ធសាសនាខ្មែរត្រូវបង្ខំឱ្យរៀនទ្រឹស្តីហូជីមិញជាចម្បង និងមានការហាមឃាត់ការទាក់ទងរវាងព្រះសង្ឃពីវត្តមួយទៅវត្តមួយ ការរស់នៅរបស់ព្រះសង្ឃ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោមស្ថិតនៅក្នុងការភ័យខ្លាច ។

ចំពោះបំណងល្អរបស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមដែលថា នឹងរៀបចំឱ្យមានដំណើរទស្សនកិច្ចរបស់អ្នកកាសែតទៅកាន់តំបន់ប្រជារាស្ត្រខ្មែររស់នៅដើម្បីបានឃើញទិដ្ឋភាពជាក់ស្តែងនោះសហគមន៍ខ្មែរកម្ពុជាក្រោមយល់ឃើញថា រដ្ឋាភិបាលវៀតណាមគួរតែបើកទូលាយឱ្យក្រុមសិទ្ធិមនុស្សជាតិ និងអន្តរជាតិ និងបណ្តាញសារព័ត៌មានសេរីចុះទៅដល់ទីកន្លែងប្រជារាស្ត្រខ្មែររស់នៅផ្ទាល់ដោយសេរីដោយពុំមានការរៀបចំទើបជាការល្អប្រសើរ ។

ជាមួយគ្នានេះលោកសុន ឆ័យ ក្នុងនាមជាប្រធានគណៈកម្មការកិច្ចការបរទេសនៃរដ្ឋសភាក៏បានដាក់លិខិតដល់ឯកអគ្គរដ្ឋទូតវៀតណាមប្រចាំកម្ពុជាសុំជួបដើម្បីពិភាក្សាការងារមួយចំនួន និងសុំការអនុញ្ញាតបានចុះទៅជួបដោយផ្ទាល់ជាមួយលោកទឹម សាខន។ នៅក្នុងលិខិតរបស់លោកបានសរសេរថា មន្ត្រីជំនួយការគណៈកម្មការកិច្ចការបរទេសនៃរដ្ឋសភាបានទាក់ទងទៅស្ថានទូតនាព្រឹកថ្ងៃទី២៧ សីហា ស្នើសុំពេលវេលាដើម្បីជួបពិភាក្សាការងារផ្ទាល់លើកិច្ចការមួយចំនួន ក្នុងនោះមានករណីពាក់ព័ន្ធនឹងដំណើរទស្សនកិច្ចនៃគណៈកម្មការកិច្ចការបរទេសនៃរដ្ឋសភាវៀតណាមមកកម្ពុជាដែលបានស្នើឡើងនៅកិច្ចប្រជុំ AIPA ប្រទេសម៉ាឡេស៊ី ហើយបញ្ហាសំខាន់មួយចំនួនទៀតពាក់ព័ន្ធនឹងពលរដ្ឋ និងព្រះសង្ឃខ្មែរកម្ពុជាក្រោម ។ លិខិតដដែលបន្តថា ដោយសារមិនអាចជួបបានក្នុងសប្តាហ៍នេះ ដោយហេតុថា ឯកឧត្តមជាប់រវល់រៀបចំពិធីបុណ្យឯករាជ្យជាតិរបស់វៀតណាមនោះ លោកក៏នៅតែសង្ឃឹមថា នឹងមានការជួបពិភាក្សាការងារនៅថ្ងៃខាងមុខឱ្យបានឆាប់តាមដែលអាចធ្វើបាន ព្រោះមានសារសំខាន់សំរាប់កិច្ចសហប្រតិបត្តិការល្អរវាងរដ្ឋាភិបាល និងសភានៃប្រទេសទាំងពីរ ៕ *ស.សុខុម*